# ការផ្លាស់ប្តូរ៖ ការចាប់ផ្តើម ចូលរៀនដោយមានទំនុកចិត្ត

## គោលការណ៍ណែនាំដើម្បីជួយដល់គ្រួសារក្នុងការបំពេញរបាយការណ៍ស្តីពីការផ្លាស់ប្តូរលើការរៀនសូត្រ និងការអភិវឌ្ឍ

### ហេតុអ្វីបានជាការចាប់ផ្តើមចូលរៀនដោយមានទំនុកចិត្តមានសារៈសំខាន់?

ការចាប់ផ្តើមចូលរៀនដោយមានទំនុកចិត្ត នាំទៅរកលទ្ធផលរៀនសូត្រ និងសុខុមាលភាពល្អប្រសើរសម្រាប់កូនរបស់អ្នក។ វា៖

- ជៀសវាងការរំខានដល់ការរៀនសូត្រ និងការអភិវឌ្ឍរបស់ពួកគេ
- ជួយឱ្យកូនរបស់អ្នកមានអារម្មណ៍សុវត្ថិភាព ទំនុកចិត្ត និងភ្ជាប់ទំនាក់ទំនង
- បង្កើនភាពស៊ាំថ្មីក។

### តើអ្វីទៅជា របាយការណ៍ស្តីពីការផ្លាស់ប្តូរលើការរៀនសូត្រ និងការអភិវឌ្ឍ?

របាយការណ៍ស្តីពីការផ្លាស់ប្តូរលើការរៀនសូត្រ និងការអភិវឌ្ឍ (ត្រូវបានគេស្គាល់ថារបាយការណ៍ស្តីពីការផ្លាស់ប្តូរ) ត្រូវបានសរសេរសម្រាប់កុមារគ្រប់រូប នៅពេលពួកគេផ្លាស់ប្តូរពីសេវាកម្មអប់រំកុមារតូច ឆ្ពោះទៅសាលារៀន។ របាយការណ៍ស្តីពីការផ្លាស់ប្តូរ ធ្វើឱ្យមានភាពងាយស្រួលក្នុងការចែករំលែកព័ត៌មានរវាងសេវាកម្ម សាលារៀន និងគ្រួសារ។

របាយការណ៍ស្តីពីការផ្លាស់ប្តូររបស់កូនអ្នក នឹងរួមបញ្ចូល៖

- ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងរូបថតរបស់កូនអ្នក
- ឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់អ្នក
- ឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់សេវាកម្មអប់រំកុមារតូច និងអ្នកជំនាញផ្នែកអប់រំកុមារតូចឯទៀតណា ដែលកំពុងគាំទ្រកូនរបស់អ្នក
- ព័ត៌មានអំពីចំណាប់ចំណូលចិត្ត ជំនាញ និងសមត្ថភាពរបស់កូនអ្នក
- យុទ្ធសាស្ត្របង្រៀនដើម្បីគាំទ្រការរៀនសូត្ររបស់កូនអ្នក។

ព័ត៌មាននេះជួយគ្រូថ្នាក់ត្រៀមរបស់កូនអ្នក ឱ្យស្គាល់កូនរបស់ អ្នក និងរៀបចំផែនការរៀនរបស់ពួកគេ។ របាយការណ៍ស្តីពីការផ្លាស់ប្តូរ អាចជួយអ្នកស្វែងយល់ គាំទ្រ និងពិភាក្សាអំពីការរៀនសូត្ររបស់កូនអ្នក នៅពេលពួកគេចាប់ផ្តើមចូលរៀន។

ប្រសិនបើកូនរបស់អ្នកនឹងទៅមជ្ឈមណ្ឌលថែទាំកុមារក្រៅម៉ោងសាលា (OSHC) សេវាកម្ម OSHC ក៏នឹងបានទទួលច្បាប់ចម្លងនៃរបាយការណ៍ស្តីពីការផ្លាស់ប្តូរផងដែរ។

របាយការណ៍ស្តីពីការផ្លាស់ប្តូររបស់កូនអ្នក ជួយ៖

- រៀបចំផែនការសម្រាប់ចំណាប់ចំណូលចិត្តរបស់កូនអ្នក
- ជួយទំនុកបម្រុងដល់ការផ្លាស់ប្តូរដោយរលូនពីសេវាកម្មកុមារតូចរបស់កូនអ្នក ទៅសាលារៀន។

### មតិយោបល់របស់អ្នក មាននៅក្នុងរបាយការណ៍ស្តីពីការផ្លាស់ប្តូរ

អ្នកអាចជួយកូនរបស់អ្នក ឱ្យមានការចាប់ផ្តើមចូលរៀនដោយ មានទំនុកចិត្ត ដោយរួមចំណែកក្នុងរបាយការណ៍ស្តីពីការផ្លាស់ ប្តូររបស់ពួកគេ។

របាយការណ៍ស្តីពីការផ្លាស់ប្តូរ មានផ្នែកនានាសម្រាប់មនុស្សផ្សេងៗគ្នាដែលត្រូវបំពេញ៖

**ផ្នែកទី 1 និង 1.1** ត្រូវបំពេញដោយអ្នកអប់រំកុមារតូចរបស់កូនអ្នក។

**ផ្នែកទី 1.2** អាចបំពេញដោយអ្នកអប់រំកុមារតូចរបស់កូនអ្នក ប្រសិនបើកូនរបស់អ្នកមានការអភិវឌ្ឍយឺតយ៉ាវ ឬមានពិការភាព។ អ្នកជំនាញផ្នែកអប់រំកុមារតូចផ្សេងទៀត ដែលជួយគាំទ្រដល់កូនរបស់អ្នក ក៏អាចចូលរួមចំណែកផងដែរ។

**ផ្នែកទី 2: កុមារ** ត្រូវបំពេញដោយកូនរបស់អ្នក ដោយមានជំនួយពីមនុស្សពេញវ័យដែលពួកគេស្គាល់ ដូចជាអ្នក ឬអ្នកអប់រំកុមារតូច។

**ផ្នែកទី 3: គ្រួសារ** គឺសម្រាប់អ្នកបំពេញ។ វាស្នើសុំទស្សនៈសំខាន់ៗរបស់អ្នក អំពី៖

- ចំណង់ចំណូលចិត្តរបស់កូនអ្នក
- ក្តីសង្ឃឹម បំណងប្រាថ្នា និងគោលដៅសម្រាប់កូនរបស់អ្នកនៅសាលារៀន។

ព័ត៌មាននេះអាចជួយគ្រូរបស់កូនអ្នក (និងអ្នកអប់រំ OSHC របស់ពួកគេ ប្រសិនបើពួកគេមាន) ដើម្បីប្រាស្រ័យទាក់ទងជាមួយអ្នក និងកូនរបស់អ្នក ហើយគាំទ្រដល់ការរៀនសូត្រ និងការអភិវឌ្ឍរបស់កូនអ្នក។

## តើមានអ្វីកើតឡើងបន្ទាប់?

ប្រគល់ផ្នែកទី 3 ដែលបានបំពេញដោយអ្នក (និងផ្នែកទី 2 ប្រសិនបើអ្នកបានជួយកូនរបស់អ្នកបំពេញ) ទៅឱ្យអ្នកអប់រំកុមារតូចរបស់កូនអ្នក។

ពួកគេនឹងចងក្រងផ្នែកទាំងអស់ នៃរបាយការណ៍ស្តីពីការផ្លាស់ប្តូរ ហើយផ្តល់សេចក្តីចម្លងមួយច្បាប់ទៅ៖

- អ្នក
- សាលារៀនរបស់កូនអ្នក
- សេវាកម្ម OSHC របស់កូនអ្នក ប្រសិនបើពួកគេមាន

ប្រសិនបើអ្នកមិនទាន់បានជ្រើសរើសសាលារៀននៅឡើយ អ្នកនឹងត្រូវបានគេផ្តល់ជូនច្បាប់ចម្លងទីពីរ នៃរបាយការណ៍ស្តីពីការផ្លាស់ប្តូរ ។ អ្នកអាចផ្តល់ច្បាប់ចម្លងនេះទៅសាលារៀន នៅពេលអ្នកចុះឈ្មោះកូនរបស់អ្នក។

ប្រសិនបើអ្នកមិនបញ្ជូនផ្នែកទី 3 មកវិញទេ អ្នកអប់រំកុមារតូចនឹងនៅតែចែករំលែករបាយការណ៍ស្តីពីការផ្លាស់ប្តូរ ដែលនៅសល់ដែលបានបំពេញជាមួយអ្នក សាលារៀនរបស់កូនអ្នក និងសេវាកម្ម OSHC របស់កូនអ្នក ប្រសិនបើពួកគេមាន។

ការចែករំលែកព័ត៌មាននៅក្នុងរបាយការណ៍ស្តីពីការផ្លាស់ប្តូរ ជួយឱ្យកុមារផ្លាស់ប្តូរ ទៅសាលារៀនដោយជោគជ័យ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកមិនចង់ឱ្យគេចែករំលែករបាយការណ៍ស្តីពីការផ្លាស់ប្តូរ ជាមួយសាលារៀនរបស់កូនអ្នកទេ សូមនិយាយជាមួយអ្នកអប់រំកុមារតូចរបស់អ្នក។

ពេលខ្លះ អ្នកជំនាញផ្នែកអប់រំ និងថែទាំវិចថ្មរៀ ត្រូវមានការចែករំលែកព័ត៌មាន ដើម្បីការពារសុខុមាលភាព ឬសុវត្ថិភាព កុមារ។ សេវាកម្មអប់រំកុមារតូចរបស់អ្នក អាចចែករំលែកព័ត៌មានអំពីកូន និងគ្រួសាររបស់អ្នកនៅពេលចាំបាច់ ដើម្បីបំពេញកាតព្វកិច្ចថែទាំ ប្រឆាំងការរើសអើង សុខភាព និងសុវត្ថិភាពពាក់ព័ន្ធនឹងការងារ ហើយនិងកាតព្វកិច្ចសុខុមាលភាព និងសុវត្ថិភាពកុមារ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល https://www.vic.gov.au/information-sharing-schemes-and-the-maram-framework

## សម្រាប់ព័ត៌មានបន្ថែម

សូមចូលមើល www.education.vic.gov.au/transitiontoschool

ឯកសារនេះមានជាភាសាផ្សេងៗនៅតាមគេហទំព័រ www.education.vic.gov.au/transitiontoschool។